# វិធីការកម្ចាត់ចៃ Phylloxera និងឧបករណ៍ ប្រើដោយដៃ ព្រមទាំងស្បែកជើងធ្វើការ

ជនរាល់រូប ដែលបានទៅមើលចម្ការទំពាំងបាយជូរមួយផ្សេងទៀត មុននឹងចូលមកចម្ការទំពាំងបាយជូររបស់អ្នក អាចដោយមកជាមួយនូវចៃបំផ្លាញទំពាំងបាយជូរ (phylloxera) គ្រាប់ស្មៅចង្រៃទាំងពួង និងសត្វល្អិតចង្រៃដទៃទៀត ក៏ដូចជាជំងឺផ្សេងៗទៀតផងដែរ។ វិធានការដ៏សំខាន់មួយដើម្បីការពារចម្ការទំពាំងបាយជូររបស់អ្នក គឺត្រូវធានាឱ្យបានថា ជនគ្រប់រូបដែលចូលមកចម្ការអ្នក ប្រើសម្លៀកបំពាក់ស្អាត ហើយស្បែកជើងរបស់ពួកគាត់ក៏ត្រូវតែស្អាត ដោយការលាងសម្អាតរោគឬកម្ចាត់ចៃ។ ដំណើរការសម្អាតរោគឬកម្ចាត់ចៃត្រូវតែធ្វើឡើងជាដាច់ខាត មុនពេលដែលភ្ញៀវណាម្នាក់ដើរមកក្បែរចម្ការទំពាំងបាយជូររបស់អ្នក និងក្រោយពេលដែលភ្ញៀវរូបនោះចាកចេញពីចម្ការរបស់អ្នក ដោយអនុវត្តតាមក្បួន "ចូលស្អាត ចេញស្អាត"។ ដំណើរការដូចគ្នានេះ ក៏ត្រូវបានណែនាំផងដែរ ក្នុងការសម្អាតកន្ត្រៃកាត់មែកឈើតូចៗ និងកន្ត្រៃកាត់ច្រឹបផ្លែទំពាំងបាយជូរ ព្រមទាំងចបប៉ែលនានា ក៏ដូចជាកូនឧបករណ៍ប្រើដោយដៃដទៃទៀត ដែលបានប្រឡាក់ប៉ះពាល់ដី និងគ្រឿងសម្ភារៈដែលប្រើក្នុងកិច្ចការដំណាំនិងប្រមូលទិន្នផលទំពាំងបាយជូរ។

*កំណត់ចំណាំ៖វិធីការកម្ចាត់ជំងឺនេះ អាចយកទៅអនុវត្តសម្រាប់កម្ចាត់សត្វល្អិតចង្រៃនិងជំងឺដទៃទៀត ក៏ប៉ុន្តែការប្រើថ្នាំ ក្លរីន និងថ្នាំដេថុល ក្នុងការកម្ចាត់រោគឬកម្ចាត់ចៃនៅទីនេះ គឺប្រើតែចំពោះចៃទំពាំងបាយជូរ phylloxera ប៉ុណ្ណោះ។  បើមានការដឹកជញ្ជូនឧបករណ៍ទាំងនេះឆ្លងរដ្ឋ ឬតំបន់គ្រប់គ្រងចៃ phylloxera ចូរឆែកមើលជម្រើសនៃការលាងសម្អាតដែលត្រូវអនុវត្ត នៅតាមរដ្ឋដែលពាក់ព័ន្ធ។*

## ការកម្ចាត់រោគនៅពេលចូលនិងពេលចេញពីចម្ការរបស់អ្នក

### បញ្ជីនៃគ្រឿងសម្ភារៈដែលត្រូវមាន

- ធុងឬឡាំងដ៏មាំដែលមានគម្រប
- ថ្នាំក្លរីន ឬដេថុល
- ទឹក
- ស្រោមដៃ
- វ៉ែនតាសុវត្ថិភាព
- ច្រាសដុស

### អ្វីដែលត្រូវធ្វើ

| | |
|---|---|
| ជំហានទី 1 - លាង | **មុននឹងចូលទៅក្នុងចម្ការអ្នក** –ត្រូវប្រើទឹកលាងសម្អាតដីនិងកម្ទេចរុក្ខជាតិ<br>**ពេលចេញ** –ប្រើទឹក និងច្រាសដុស(ឬទួរណឺវីស) ដើម្បីផ្ទិះជម្រុះដី និងកម្ទេចរុក្ខជាតិចេញពីក្រឡាស្បែកជើង។ |
| ជំហានទី 2 – លាយ | ចាក់ថ្នាំដេថុលសុទ្ធឬចាក់ល្បាយរាវនៃថ្នាំ sodium hypochlorite (ក្លរីន) ចំនួន2% ចូលទៅក្នុងឡាំង/ធុង ដោយប្រើទឹកសមល្មមអាចជ្រមុជស្បែកជើងទៅក្នុងល្បាយ រាវនោះ។ បើសិនជាប្រើផលិតផល sodium hypochlorite បរិមាណ 4% មានដូចជា White King bleach ជាដើម ចូរលាយល្បាយទឹកថ្នាំនោះ ក្នុងបរិមាណស្មើគ្នាជាមួយនឹងទឹក។ ពិនិត្យមើលកាលបរិច្ឆេទនៃសុពលភាពរបស់ផលិតផល ហើយ អនុវត្តតាមក្បួនណែនាំប្រកបដោយសុវត្ថិភាពក្នុងការប្រើប្រាស់ផលិតផល។ ចូរប្រើស្រោមដៃ និងវ៉ែនតាសុវត្ថិភាព។ |
| ជំហានទី 3 – ការទុកដាក់ | ចូរទុកដាក់ធុង/ឡាំងល្បាយថ្នាំដេថុល ឬក្លរីន នៅលើកន្លែងដែល មាំល្អ ឆ្ងាយពីចម្ការទំពាំងបាយជូរ-យកល្អដាក់នៅក្នុងរោងការិយាល័យ ឬមាត់ច្រកចូលនៃចម្ការ។ |
| ជំហានទី 4 – ជ្រមុជ | ត្រូវពន្លិចឬជ្រមុជស្បែកជើងទៅក្នុងល្បាយថ្នាំនោះ ហើយត្រាំឱ្យយ៉ាតិច60 វិនាទី នៅក្នុងល្បាយថ្នាំដេថុលឬក្លរីននោះ។ ក្រោយពីត្រាំល្បាយថ្នាំនោះរួច សូមកុំលាងជម្រះជាតិថ្នាំឱ្យ សោះ។ តោងប្រយ័ត្នកុំឱ្យល្បាយថ្នាំខ្ទាតចូលភ្នែក ស្បែក និង សម្លៀកបំពាក់។ |
| ជំហានទី 5 –គ្រប | ចូរយកគម្របគ្របឡាំង/ធុងល្បាយថ្នាំដេថុលឬក្លរីន នៅក្នុងពេលថ្ងៃ ដើម្បីកុំឱ្យពន្លឺព្រះអាទិត្យបំផ្លាញកម្លាំងប្រសិទ្ធិពលថ្នាំ។ ប្តូរល្បាយថ្នាំនេះជារៀងរាល់ថ្ងៃ ឬញឹកញាប់ជាងនេះ បើសិន ជាល្បាយនេះមានភាពល្អក់កខ្វក់។ |
| ជំហានទី 6 – ចោល | ចូរចាក់ចោលល្បាយថ្នាំនេះ នៅកន្លែងដីហាប់ណែន ឬកន្លែងដែលគេលាងដុសដោយមានប្រព័ន្ធបង្ហូរទឹកកខ្វក់ចោលត្រឹមត្រូវ ឆ្ងាយពីចម្ការ និងតំបន់ដែលមានយានយន្តនិងមនុស្សចរាចរ។ |

### របៀបធ្វើ




### ដំបូន្មានមានប្រយោជន៍

1. រៀបចំបង្កើតកន្លែងកម្ចាត់ជំងឺរបស់អ្នក ដើម្បីធានាឱ្យបាននូវលំហូរសណ្តាប់ធ្នាប់ ការងារចាប់ពីកន្លែងលាងដុសសម្អាត ដល់កន្លែងទុកដាក់ថ្នាំដេថុលឬក្លរីន រហូតដល់ទីធ្លាចម្ការទំពាំងបាយជូរ។ បន្ទាប់មកចាប់ពីទីធ្លាចម្ការរហូតដល់ កន្លែងសម្អាតលាងដុសចូលទៅដល់ កន្លែងល្បាយថ្នាំក្លរីនឬដេថុល និងពេល ចាកចេញ ដោយចៀសវាងការដើរលើ ដីមុននឹងចូលទៅកន្លែងកម្ចាស់ជំងឺ។
2. ភ្ញៀវទាំងឡាយត្រូវតែឈរត្រាំក្នុងល្បាយទឹកថ្នាំដេថុលឬក្លរីនឱ្យបាន60វិនាទី។ ចូរគិតអំពីរបៀបផ្ទៀងម៉ោងឱ្យបានគ្រប់ចំនួនកំណត់។ អ្នកអាច ប្រើពេល60វិនាទីនេះនិយាយអំពីសុខភាពដើម ទំពាំងជូរ នៅពេលភ្ញៀវម្នាក់ៗឈរត្រាំជើង។
3. ដំណើរការកម្ចាត់ជំងឺនឹងមិនសូវមានប្រសិទ្ធភាពទេ បើសិនជាល្បាយថ្នាំដេថុលឬក្លរីនឡើង សភាពល្អក់កខ្វក់។ ការធានាឱ្យបាននូវការលាង ត្រដុសស្បែកជើងជម្រុះដីនិងកម្ទេចឈើ មុន នឹងការលាងសម្អាតនិងត្រាំជើងក្នុងល្បាយទឹកថ្នាំ គឺមានសារៈសំខាន់ណាស់។

### ជម្រើសផ្សេងទៀតដើម្បីកម្ចាត់រោគ

ចូរផ្តល់ឱ្យភ្ញៀវនូវស្បែកជើងឃ្លុបកវែងដើម្បីពាក់នៅក្នុងទីធ្លាចម្ការរបស់អ្នកឬក៏ទន្រាប់ដ៏មាំមួនសម្រាប់គ្របជើង។ តម្រូវឱ្យអ្នកម៉ៅពលកម្ម រក្សាទុកស្បែកជើងឃ្លុបកវែងមួយគូនៅក្នុងចម្ការរបស់អ្នក ដោយប្តូរពាក់ស្បែកជើងមួយគូផ្សេងទៀត នៅពេលពួកគេចាកចេញ។ ស្បែកជើង កវែងដែលត្រូវពាក់នៅក្នុងចម្ការទំពាំងបាយជូរនេះ ត្រូវសម្អាតតែម្តងទេ គឺពេលគេយកវាចូលមកកាន់ចម្ការនេះជាលើកដំបូង។

VINEHEALTH AUSTRALIA

ចំពោះព័ត៌មានបន្ថែមសូមទាក់ទង៖ VINEHEALTH AUSTRALIA | 08 8273 0550 | ADMIN@VINEHEALTH.COM.AU | WWW.VINEHEALTH.COM.AU

© Vinehealth Australia 2023